# វត្តអាងថ្មបីដុំ ភ្នំត្បែង

វត្តអាងថ្មបីដុំ ស្ថិតនៅលើភ្នំត្បែង ក្នុងភូមិសាស្ត្រ ភូមិក្តី ឃុំអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ។ ដែលមានចំនុចនិយាមការ X 490382 Y 1510503 មានកម្ពស់៤៩៥ម៉ែត្រធៀបនិងទឹកសមុទ្រ (រូបលេខ១)។ វត្តអាងថ្មបីដុំអាចធ្វើដំណើរឡើងពីខាងស្រុកសង្គមថ្មី ឬក៏ឡើងតាមវត្តដំបូកខ្មៅ និងបន្តដំណើរមកកាន់វត្តថ្ម៣ដុំ ដោយថ្មើរជើងឬម៉ូតូប្រមាណ៥គីឡូម៉ែត្រ។ ភ្នំត្បែងត្រូវបានរាជរដ្ឋាភិបាល បានដាក់ជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ដោយអនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ដែលមានផ្ទៃដី ២៥២៦៩,៤១ហិកតា។[1] វត្តអាងថ្មបីដុំខ្លះហៅកាត់ថាវត្តថ្មបីដុំ (រូបលេខ២) ជាទីតាំងជំនឿខាងសាសនាដ៏សំខាន់មួយនៅលើភ្នំត្បែង។ ហេតុអ្វីបានជាគេហៅថាវត្តថ្ម៣ដុំ?

ថ្មបីដុំត្រូវបានហៅទៅតាមឈ្មោះថ្មធំៗ៣ដុំ មានសណ្ឋានដូចជាមុំចង្ក្រានដែលស្ថិតនៅខាងត្បូងព្រះវិហារលើកំពូលភ្នំត្បែង(រូបលេខ៣)។ ក្នុងចំណោមថ្មទាំងបីដុំ មានមួយដុំមានសិលាចារឹកចារជាភាសាសំស្ក្រឹតចំនួន១០បន្ទាត់។ សិលាចារឹកនេះ មានភាពបែកនៅផ្នែកខាងឆ្វេង និងខាងក្រោម ផ្នែកកណ្តាលមានស្នាមដាប់។ សិលាចារឹកនេះ អាចចារក្នុងអំឡុងស.វទី១០-១១នៃគ.ស ដែលចាប់ផ្តើមដោយ នមស្ការចំពោះព្រះសិវៈ នៅបន្ទាត់ទី៦ក៏មាននិយាយអំពីសិវៈបុត្រ ក្នុងន័យនេះអាចជាទីតាំងនេះមានការគោរពចំពោះព្រះសិវៈ ឬព្រះឥសូរ(រូបលេខ៤)។ យើងបានឃើញកស្តុតាងដូចជាបល្ល័ងនៃលិង្គព្រះឥសូរ (ចម្លាក់បុរាណ) និងចម្លាក់លិង្គព្រះឥសូរដែលគេឆ្លាក់ថ្មីចំនួន២ (រូបលេខ៥)។ នៅផ្នែកខាងក្រោមនៃថ្ម៣ដុំមានល្អាង១ហៅថាល្អាងព្រះខែ(រូបលេខ៦) នៅក្នុងល្អាងមានឆ្លាក់ជាចម្លាក់ក្បាច់លំអមួយរាងមូលនៅចំកណ្តាលជាក្បាច់ផ្កាឈូករីក នៅជុំវិញមានផ្កាឈូករីកតូចៗ និងមានរូបថូទឹកដុះចេញផ្កាឈូក៣ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងចម្លាក់ត្រីសូល៌។ អ្នកស្រុកខ្លះគាត់ហៅថាយ័ន្ត ដែលមានរូបដូចជាព្រះខែ (រូបលេខ៧) ទើបគេហៅល្អាងនេះថាជាល្អាងព្រះខែ។ នៅផ្នែកខាងក្រោយនៃល្អាងមានសិលាចារឹកនៅខាងក្រោយថ្មចំនួន២បន្ទាត់ចារនៅខាងក្រោយដែលនៅខាងចុងនៃឃ្លានៅ...ព្រះឥន្ទ្រគុហារ(រូបលេខ៨)។ នេះអាច

[1] ២០១៦, អនុក្រឹត្យ ១៨៩អនក្រ.បក

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ជាឈ្មោះនៃល្អាងព្រះខែនេះ តាមរយៈអក្សរមានលក្ខណៈដូចគ្នានឹងសិលាចារឹកដែលចារលើថ្ម៣ដុំដែលអាចចារក្នុងអំឡុងស.វទី១០-១១គ.ស។ ក្នុងន័យនេះអាចបញ្ជាក់ថាទីតាំងនេះជាទីតាំងគោរពបូជា ខាងព្រហ្មញ្ញសាសនា ក្នុងសម័យអង្គរ។ ភស្តុតាងមួយចំនួនទៀតដូចជាសន្ទុងជាទីតាំងដែលមានថ្មភក់រៀបចំដូចជាឃឿនប្រាសាទ (រូបលេខ៩) ជាទីកន្លែងដែលត្រូវបានរៀបចំសម្រាប់ដម្កល់ព្រះ ទីតាំងនេះត្រូវបានជួសជុលឡើងវិញក្នុងអំឡុងឆ្នាំ១៩៦២ (រូបលេខ១០) តាមរយៈអក្សរដែលចារលើកំបោរបាយអរ បច្ចុប្បន្នមានដាក់ព្រះពុទ្ធរូប និងសំណាត់ឈើនៅខាងលើ។ តើសំណង់អាចសាងសង់ពីមុនមកក្នុងសម័យអង្គរឬយ៉ាងណា? យើងបានឃើញស្នាកស្នាមកាប់ថ្មពីទីតាំងនៅក្បែរនោះ (រូបលេខ១១)។ តាមរយៈលោកអាចារ្យ ហាម ប៉ែន បាននិយាយថាមានចម្លាក់ព្រះព្រហ្មកាលពីមុន ត្រូវបានគេវាយបំបែកនិងលួចយកព្រះកេសទៅបាត់(រូបលេខ១២)។ ក្រោយមកក៏បានឆ្លាក់ជាព្រះកេសថ្មីអំពីថ្មក្នុងអំឡុងឆ្នាំ១៩៩៥? (រូបលេខ១៣)។ បំណែកនៃរូបទី១២ ដែលតាមរយៈលោកអាចារ្យនោះបានដាក់នៅក្រោមបុស្សបុក អាចជារូបនៃព្រះពុទ្ធរូបចតុមុខ សាងអំពីថ្មភក់ មានលាភម្រ័ក្ស ដែលឃើញមានដូចជានៅព្រះពុទ្ធត្រឡេងកែងនៅបន្ទាយលង្វែក ប្រាសាទចតុមុខនៅព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ។ តាមរយៈចម្លាក់នេះថាតើអាចជាស្នាដៃនៃសិល្បៈសម័យកណ្តាលដែរឬទេ? នៅលើភ្នំត្បែងក៏មានទីតាំងមួយដែលហៅថាព្រះបាទតែចម្លាក់នៃព្រះបាទពុំមានក្បាច់លំអ និងសិករិចរិល។ នៅខាងលិចព្រះវិហារក៏មានស្រះទឹកបុរាណមួយដែលមានទឹកខ្វបប្រាំងខ្វបវស្សា។

រួមសេចក្តីមកទីតាំងវត្តថ្មបីដុំ ជាទីតាំងដែលប្រជាជនខ្មែរបានគោរបបូជាតាំងពីសម័យអង្គរ ខាងផ្នែកព្រហ្មសាសនា ជាទីតាំងសម្រាប់ធ្វើតបៈធម៌ពីសម័យអង្គរបន្តមកសម័យកណ្តាល និងមកដល់ពេលបច្ចុប្បន្ន៕

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ




រូបទី១



រូបលេខ២៖ តាំងជំនឿខាងសាសនាដ៏សំខាន់មួយនៅលើភ្នំត្បែង (ប្រភពព្រះតេជគុណ សំ សោភ័ណ)

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៣៖ ទីតាំងថ្មបីដុំ



រូបលេខ២៤៖ សិលាចារឹកចារលើថ្មមួយដុំក្នុងចំណោមថ្មបីដុំ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៥៖ ជើងទម្រលិង្គព្រះឥសូរ (ចម្លាក់បុរាណ) និងចម្លាក់លិង្គព្រះឥសូរដែលគេឆ្លាក់ថ្មីចំនួន២



រូបលេខ៦៖ ល្អាងព្រះខែ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៧៖ អ្នកស្រុកខ្លះគាត់ហៅថាយ័ន្ត រូបដូចជាព្រះខែ



រូបលេខ៨៖ សិលាចារឹកចារនៅផ្នែកខាងក្រោយនៃល្អាងព្រះខែ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៩៖ សន្ទុងជាទីតាំងដែលមានថ្មកក់រៀបចំដូចជាឃឿនប្រាសាទ



រូបលេខ១០៖ ទីតាំងដម្កល់ព្រះ និងជាទីតាំងបានជួសជុលឡើងវិញក្នុងអំឡុងឆ្នាំ១៩៦២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១១៖ ស្នាកស្នាមកាប់ថ្ម



រូបលេខ១២-១៣៖ ចម្លាក់ព្រះព្រហ្មគេវាយបំបែកលួចយកព្រះកេស
និងក្រោយមកក៏បានឆ្លាក់ជាព្រះកេសថ្មី ក្នុងអំឡុងឆ្នាំ១៩៩៥?

អត្ថបទដោយ៖ លឹម វណ្ណចន្ទ